ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០១៦

**សេចក្តីផ្តើម :**

នៅក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០១លើក និងប្រជុំពេញអង្គចំនួន០១លើក ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីស្នើសុំលើកអភ័យឯកសិទ្ធិសមាជិកាព្រឹទ្ធសភា០១រូប<br>- ការពិគ្រោះយោបល់ជាមួយលោក Vincent Eblee អំពីពង្រាងក្រមសីលធម៌ ការតាក់តែងសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងថ្មី ការត្រៀមបន្តនីតិវិធីពាក់ព័ន្ធសេចក្តីស្នើច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល បម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំចំនួន០២លើក មានអ្នកចូលរួមចំនួន១០៥នាក់<br>- ថតចម្លងឯកសារបានចំនួន១៧សំណើ អស់ក្រដាសចំនួន២០,០២៣សន្លឹក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន ២៥នាក់ ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | ព្រឹទ្ធសភាថ្មី និងសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី២<br>- បានសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០២ ដែលបានទទួលពីរាជរដ្ឋាភិបាល<br>- បន្តធ្វើបច្ចុប្បន្នភាពបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងបន្តសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន០៧ច្បាប់<br>- បានស្រាវជ្រាវអំពីនីតិវិធីក្នុងការតាក់តែងច្បាប់របស់សភាប្រទេសទាំង១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍<br>- បានរៀបចំទីកន្លែងប្រជុំចំនួន១២លើក ត្រួតពិនិត្យប្រព័ន្ធសំឡេង ម៉េក្រូហ្វូន កាមេរ៉ាវីដេអូសុវត្ថិភាពចំនួន១២៣លើក ថត និងផ្សព្វផ្សាយព័ត៌មានសេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន៨៥លើក បង្ហោះលើគេហទំព័រព្រឹទ្ធសភា និងផលិតជា Video online ចំនួន៣៥លើក ។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបានៈ<br>+ អញ្ជើញជួបសវនាការជាមួយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យពិភាក្សាអំពីគម្រោងថវិកាសម្រាប់ឆ្នាំ២០១៧របស់ព្រឹទ្ធសភា ស្វែងយល់អំពី | - ថត និងផ្សព្វផ្សាយព័ត៌មានសកម្មភាពរបស់សមាជិកសមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន០២លើក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការអមដំណើរសមាជិកព្រឹទ្ធសភា |

| | |
|---|---|
| ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់និយោជក និងនិយោជិត ព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាព បច្ចេកទេស និងវិជ្ជាជីវៈឲ្យរីកចម្រើនស្របតាមបទដ្ឋានអន្តរជាតិ និងការការពារពលករខ្មែរ ដែលត្រូវបញ្ជូនទៅធ្វើការនៅបរទេស<br>+ អញ្ជើញចុះទៅតាមដានការអនុវត្តច្បាប់ និងសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន នៅតាមខណ្ឌទាំង០៧ រាជធានីភ្នំពេញ<br>+ អញ្ជើញចុះជួបពិភាក្សាការងារ ដើម្បីស្វែងយល់អំពីវឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពរថ្មីៗ នៅខេត្តកណ្ដាល<br>+ អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន នៅភូមិភាគទី៧ ខេត្តកំពង់ឆ្នាំង ។ | ចុះទៅសិក្សាស្វែងយល់អំពីការអនុវត្តច្បាប់ចំនួន១២នាក់ ស្មើនឹង០២ច្បាប់<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន០៦ច្បាប់ ។ |

**៣.មុខងារតំណាង** :

| វេទនាសម្ព័ន្ធនយោបាយ | វេទនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបាន៖<br>+ អញ្ជើញទទួលព្រះរាជដំណើររបស់ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា យាងនិវត្តន៍មកដល់មាតុប្រទេស បន្ទាប់ពីបានយាងពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន<br>+ អញ្ជើញជួបសំណេះសំណាល សាកសួរ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីភាព ក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន៣២៧លើក<br>- បានធ្វើកំណត់បង្ហាញ និងបញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន ០៣ករណី<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងសាធារណៈ និងការចុះស្រាវជ្រាវព័ត៌មាន ពិធីសម្ពោធអណ្តូងទឹកស្អាត និងជួបសំណេះ |

សុខទុក្ខជាមួយមន្ត្រីរាជការ មន្ត្រីចូលនិវត្តន៍ ចៅសង្កាត់ មន្ត្រីភូមិ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ កុមារកំព្រា សិល្បករ កម្មករ កម្មការិនី ក្រុមភ្លេង ក្រុមអ្នកបច្ចេកទេសចិន ដូនជី តាជី គណៈកម្មការវត្ត ប្រជាពលរដ្ឋចាស់ជរា និងអ្នករបួសពិការចំនួន ២៤លើក នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ និងខេត្តព្រះវិហារ

+ អញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសព លោក **សាន ចាន់ណាក់** អនុប្រធាននាយកដ្ឋានកិច្ចការនារី និងយេនឌ័រ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តស្រះចក និងលោក **ហេង គឹមហៃ** ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី៩ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅលំនៅដ្ឋាន រាជធានីភ្នំពេញ
+ អញ្ជើញចូលរួមក្នុងពិធីជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខេត្ត និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកំពត
+ អញ្ជើញចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍សមាគមមិត្តភាពកម្ពុជា-ចិន ស្តីពីការរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារទីស្នាក់ការសមាគមមិត្តភាពកម្ពុជា-ចិន នៅសាលប្រជុំពិសេសព្រឹទ្ធសភា
+ អញ្ជើញផ្តល់បទសម្ភាសន៍ជាមួយយុវជន

សំណាលជាមួយប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តស្វាយរៀង ។ល។

- សហការរៀបចំ និងចូលរួមពិធីបុណ្យសព លោក **សាន ចាន់ណាក់** អនុប្រធាននាយកដ្ឋានកិច្ចការនារី និងយេនឌ័រ និងលោក **ហេង គឹមហៃ** ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី៩ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានចុះសួរសុខទុក្ខមន្ត្រីជួបគ្រោះថ្នាក់ចរាចរ និងនិវត្តន៍ជនមានជំងឺនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់
- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភាចំនួន១៨២នាក់ ស្មើនឹង ៣៩ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១៣នាក់ ស្មើនឹង១៣ច្បាប់
- ថតចម្លងឯកសារចំនួន១១សំណើ អស់ក្រដាសចំនួន១,៨១២សន្លឹក
- ផ្តល់សេវាដឹកជញ្ជូន និងថវិកាសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភា ក្នុងរាជធានី និងតាមបណ្តាខេត្ត-ក្រុងទាំង៨ ភូមិភាគចំនួន៥៥៣នាក់ ស្មើនឹង៣៥លើក
- បានដោះស្រាយសំណើនានា ជូនព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៥លើក
- ទទួលលិខិតចូលចំនួន៥៨២ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១០៣ច្បាប់
- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗ ចំនួន១៥នាក់ ស្មើនឹង០២លើក
- ផ្តល់រូបថតចំនួន៨៨៥សន្លឹក សៀវភៅបត់ចំនួន

| | |
|---|---|
| សហភាពសហព័ន្ធយុវជនកម្ពុជា ខេត្តព្រៃវែង នៅសាលពិសេស២ ព្រឹទ្ធសភា<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារសមាគមមិត្តភាពកម្ពុជា-ចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៅវិមានព្រឹទ្ធសភា<br>+ អញ្ជើញនាំយកទៀនព្រះវស្សា ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាចំនួន០៣វត្ត នៅខេត្តកណ្តាល<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម S R Nathan អតីតប្រធានាធិបតីទី៦ នៃសាធារណរដ្ឋសិង្ហបុរី នៅស្ថានទូតសិង្ហបុរីប្រចាំព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញសម្ពោធអណ្តូងទឹកចំនួន០៤ នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ ព្រមទាំងស្រះទឹកចំនួន០១ នៅខេត្តព្រៃវែង ជូនប្រជាពលរដ្ឋប្រើប្រាស់ជាប្រយោជន៍សាធារណៈ<br>- បានធ្វើបទបង្ហាញស្តីពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនដល់លោកគ្រូ អ្នកគ្រូ សិស្ស និងនិស្សិត មកពីវិទ្យាស្ថានអន្តរជាតិកម្ពុជាអាស៊ានចំនួន១៨៥នាក់<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានរៀបចំវេទិកាថ្នាក់ស្រុក ស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងភូមិ ឃុំ មានសុវត្ថិភាពនៅថ្នាក់មូលដ្ឋាន នៅខេត្តត្បូងឃ្មុំ<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ | ២០០សន្លឹក និងអត្ថបទសារព័ត៌មានចំនួន ១៤២អត្ថបទ ជូនខុទ្ទកាល័យ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន៣០១នាក់ ធ្វើប័ណ្ណសមាជិកចំនួន១២រូប ខ្ចីសៀវភៅចំនួន៦៨ក្បាល និងសងវិញចំនួន១០៧ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន០១លើក របស់លោកគ្រូ អ្នកគ្រូ សិស្ស និងនិស្សិត មកពីវិទ្យាស្ថានអន្តរជាតិកម្ពុជាអាស៊ានចំនួន១៨៥នាក់<br>- ទទួលឯកសារ សៀវភៅពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ៩១១ក្បាល ព្រឹត្តិបត្រចំនួន៥៥ក្បាល ទស្សនាវដ្តីចំនួន១០២ក្បាល<br>- ផ្សព្វផ្សាយព័ត៌មានសង្ខេប និងព្រឹត្តិបត្រទស្សនព័ត៌មានប្រចាំថ្ងៃចំនួន៦១ច្បាប់។ |

| | |
|---|---|
| បានអញ្ជើញប្រជុំពិនិត្យ និងពិភាក្សាត្រៀមរៀបចំវេទិកាបូកសរុបថ្នាក់ភូមិភាគនៅខេត្តកណ្ដាល<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន០៣ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ផ្ញើជូនទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយបានចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០២ករណី និងឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០២ករណី ព្រមទាំងទទួលពាក្យបណ្ដឹងជូនជ្រាបចំនួន១៤ករណី<br>- ព្រឹទ្ធសភាបានទទួលលិខិតពីរដ្ឋសភាចំនួន០២ច្បាប់ និងពីក្រសួងស្ថាប័នពាក់ព័ន្ធចំនួន៥៩ច្បាប់<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត-រាជធានី ទូទាំងប្រទេសចំនួន២២០លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជា-ពលរដ្ឋ កងទ័ព និវត្តន៍ជន លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺដោយឥតគិតថ្លៃ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ | |

| | |
|---|---|
| ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន ៧៦លើក ។ | |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតអូស្ត្រាលី ឯកអគ្គរដ្ឋទូតចិន ឯកអគ្គរដ្ឋទូតកូរ៉េខាងជើង ឯកអគ្គរដ្ឋទូតមីយ៉ាន់ម៉ា ឯកអគ្គរាជទូតម៉ាឡេស៊ី ឯកអគ្គរាជទូតកម្ពុជា ក្រុមសិល្បករខ្មែរ មកពីសាលាវិចិត្រសិល្បៈរាជធានីភ្នំពេញ និងសិល្បករជនជាតិដើមភាគតិច មកពីខេត្តរតនគិរី ចូលជួបសម្តែងការគួរសម និងសវនាការ<br>- សមាជិក សមាជិកាព្រឹទ្ធសភាបានៈ<br>+ អនុញ្ញាតឲ្យអភិបាលខេត្តនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងសហការីចូលជួបសម្តែងការគួរសម នៅខេត្តរតនគិរី<br>+ អនុញ្ញាតឲ្យអគ្គរដ្ឋទូតតួកគី ទីប្រឹក្សាអមស្ថានទូតរុស្ស៊ី ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់អមរដ្ឋសភា ប្រធានផ្នែកអភិបាលកិច្ចល្អនៃកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់(REDIII) នៃអង្គការGIZ របស់ប្រទេសអាល្លឺម៉ង់ និងសហការី នាយកវិទ្យាស្ថានមេគង្គកម្ពុជា(MDI ) តំណាងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP) ចូលជួបពិភាក្សាការងារ<br>- សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ជួបភ្ញៀវជាតិ និងអន្តរជាតិ ចំនួន៣៣លើក<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាកេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន០៨លើក អ្នកចូលរួមចំនួន២៦៨នាក់<br>- ថតចម្លងឯកសារចំនួន០៧សំណើ អស់ក្រដាសចំនួន១,២៤៧សន្លឹក<br>- ផ្តល់សេវាថវិកាសម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីចុះបេសកកម្ម មន្ត្រីបំពេញការងារលើសម៉ោង ព្រមទាំងបានទូទាត់ថ្លៃចំណាយផ្សេងៗចំនួន ១៤លើក<br>- ផ្តល់សេវាដឹកជញ្ជូន ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីរាជការព្រឹទ្ធសភា ក្នុងរាជធានី និងតាមបណ្តាខេត្ត ក្រុងទាំង៨ភូមិភាគចំនួន ២១នាក់ ស្មើនឹង០៥លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ផ្ញើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី រៀបចំបែបបទបើកបន្ទប់ពិសេស |

| | |
|---|---|
| ទស្សនកិច្ចសិក្សា នៅសាធារណរដ្ឋកូរ៉េខាងត្បូង ចូលរួមប្រជុំក្រុមនយោបាយអាយប៉ាលើកទី៨ និងកិច្ចប្រជុំស្តីពីការធ្វើចំណាកស្រុកក្នុងប្រទេសអាស៊ាន និងការអភិរក្សសត្វព្រៃ និងធនធានធម្មជាតិ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលរួមប្រជុំអន្តរជាតិប្រចាំឆ្នាំ លើកទី២៣របស់ផ្នែកសេវាបណ្ណាល័យ និងស្រាវជ្រាវសម្រាប់សភា មហាសន្និបាតព័ត៌មាន និងបណ្ណាល័យពិភពលោកលើកទី៨២ របស់សមាគមសហព័ន្ធបណ្ណាល័យអន្តរជាតិ នៅសហរដ្ឋអាមេរិក ចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់សភាតំបន់អាស៊ី (APA) នៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន និងបានអញ្ជើញចុះជួបសំណេះសំណាលជាមួយពលករខ្មែរ នៅព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីឲ្យពួកគាត់មកចុះឈ្មោះបោះឆ្នោតថ្មី នៅព្រះរាជាណាចក្រកម្ពុជាវិញ ។ | (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូន និងទទួលដំណើរបេសកកម្មសរុបចំនួន ៣៨លើក<br>- ចេញលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការចំនួន០៩នាក់ ស្មើនឹង០៣ច្បាប់ និងបញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន៥៨ច្បាប់<br>- រៀបចំកញ្ចប់ដំណើរបេសកកម្មជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន០៦លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦៧នាក់ ស្មើនឹង០៧លើក<br>- អគ្គលេខាធិការ បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តមសេនីយ៍ឯក ផុន សារ៉ាត នាយកសាលានាយទាហានសកម្មត្មាតពង<br>- ទំនាក់ទំនងជាមួយសភាវ៉ាឡូនី ព្រុចសែលប៊ែលហ្ស៊ិក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមអគ្គលេខាធិការនិយាយភាសាបារាំង សង្គមស៊ីវិល ក្រសួង និងស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល និងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ព្រឹទ្ធសភាកំពុងអនុវត្តន៍ការសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារ |

| | |
|---|---|
| ពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន<br>- សហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន<br>- ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា បានអញ្ជើញចូលរួមប្រជុំ ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការចាត់តាំងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភានៃកម្ពុជាជាមួយសភាសហព័ន្ធមីយ៉ាន់ម៉ា ។ | ផ្សេងៗចំនួន៦៩៧ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានផ្ញើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៦៧ច្បាប់<br>- ប្រជុំអន្តរគណៈកម្មការវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំពិនិត្យសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការគ្រប់គ្រងមន្ត្រីរាជការទៅសិក្សានៅក្រៅប្រទេសនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានបញ្ចប់នីតិវិធី និងបែបបទប្រឡងតាំងស៊ប់ក្នុងមុខតំណែងមន្ត្រីរាជការចំនួន៣៥នាក់ និងបែបបទធ្វើតេស្តសមត្ថភាពបន្តកិច្ចសន្យាចំពោះបុគ្គលិកជាប់កិច្ចសន្យាចំនួន២៧៥នាក់<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និងក្រៅប្រទេសសរុបចំនួន០៨វគ្គ មានសិក្ខាកាមចូលរួមចំនួន២៣នាក់ និងសិក្ខាសាលានៅក្រៅប្រទេសចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន០៣នាក់<br>- បានបន្តអនុវត្តន៍កម្មវិធីកម្មសិក្សារបស់និស្សិតក្នុង និងក្រៅប្រទេស ( ក្រុមនិស្សិតស្ម័គ្រចិត្តកូរ៉េ KV)<br>- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល០៥ឆ្នាំ (២០១៧-២០២១)<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- រៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល |

| | |
|---|---|
| | ព្រឹទ្ធសភា (២០១៧-២០១៩)<br>- រៀបចំគម្រោងថវិកាឆ្នាំ២០១៧ និងការការពារគម្រោងថវិកាឆ្នាំ២០១៧ ក្នុងកម្រិតនយោបាយ<br>- បានរៀបចំរបាយការណ៍ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា អំពីគម្រោងថវិកាឆ្នាំ២០១៧ ក្រោយការការពារថវិកាក្នុងកម្រិតនយោបាយ<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិ ប្រចាំខែសីហា ឆ្នាំ២០១៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារ គ្រឿងអេឡិចត្រូនិចចំនួន៣១លើក ថែទាំ និងជួសជុលសម្ភារឧបករណ៍បច្ចេកទេសផ្សេងៗចំនួន០៨លើក ជួសជុលកែលម្អសោភ័ណ្ឌភាពសួនច្បារ អគារ សាលប្រជុំ ផ្លូវថ្នល់នៅក្នុងបរិវេណព្រឹទ្ធសភាចំនួន២៦លើក និងទូទាត់ការបោះពុម្ពសៀវភៅ និងឯកសារផ្សេងៗ ចំនួន១,១៦០ក្បាល ព្រមទាំងទូទាត់ថ្លៃអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗចំនួន០៥លើក<br>- ទូទាត់ថ្លៃលទ្ធកម្មថ្លៃទិញប្រេងឥន្ធនៈ ប្រចាំខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ២០១៦<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន២៧សំណើ ព្រមទាំងបានប្រគល់ និងទទួលសម្ភារផ្សេងៗចំនួន១៣សំណើ ផ្គត់ផ្គង់សម្ភារអនាម័យ ការិយាល័យ និងភេសជ្ជៈ ចំនួន៣៨សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា |

- រៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន៤១លើក មានអ្នកចូលរួមចំនួន៤១៧នាក់
- បានដោះស្រាយ និងទូទាត់សំណើនានា ជូនព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០០លើក
- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៤៥ក្បាល អស់ក្រដាសចំនួន ២៩,៧៨០សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីចំនួន៣១២នាក់ ស្មើនឹង១០៦លើក

+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:

- រៀបចំគម្រោងស្នើសុំសាងសង់អគារសាលប្រជុំពេញអង្គថ្មី (បានចាប់ផ្តើមដំណើរការបំពេញបែបបទជាផ្លូវការជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចម្លងជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទំនាក់ទំនងបែបបទជាបឋមជាមួយស្ថានទីប្រឹក្សាពាណិជ្ជកម្មចិនប្រចាំកម្ពុជា)
- បន្តតាមដាន និងត្រួតពិនិត្យជាមួយភាគីចិនលើដំណើរការការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ព្រមទាំងចាត់ចែងជួសជុលអគារសាលប្រជុំពេញអង្គចាស់ និងថ្មី
- ការងារទិន្នន័យ និងប្លង់: អនុវត្តន៍គម្រោងពាក់ព័ន្ធអគារក្រហម ចិញ្ចើមផ្លូវ កែលម្អសួនច្បារ បរិស្ថាន និងអនុវត្តន៍គម្រោងជួសជុលបន្ទប់ទឹក ( អគារក្រហម សាលសិក្ខាសាលា បណ្ណាល័យ) និងគូសប្លង់សាលប្រជុំថ្មី
- លាបថ្នាំរបងសំណាញ់ខាងមុខព្រឹទ្ធសភា និងរៀបខឿនថ្នល់អមសងខាងអគារក្រហម និងនៅសួនច្បារ

| | |
|---|---|
| | ក្រោយអគារក្រហម ព្រមទាំងស្តារប្រព័ន្ធលូ និងដាក់លូថ្មីក្នុងបរិវេណការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំ<br>- សហការចុះត្រួតពិនិត្យសត្វកណ្តៀរ នៅសាលប្រជុំអចិន្ត្រៃយ៍ សាលប្រជុំពេញអង្គ ការិយាល័យអគ្គលេខាធិការ និងនៅបណ្ណាល័យ<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចចំនួន៨៦គ្រឿង បន្ទប់ទឹក និងបណ្តាញទឹកចំនួន២២បន្ទប់/ខ្សែ<br>- បិទលេខកូដម៉ាស៊ីនត្រជាក់ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនបោកព្រំ ម៉ាស៊ីនសម្ងួត ម៉ាស៊ីនជូតម៉ាប ទូរស័ព្ទ តុ ទូ កៅអី អំភ្លី និងម៉េក្រូហ្វូនចំនួន២៣គ្រឿង<br>- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន១១លើក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន៧១គ្រឿង ។ រៀបចំមាតិកា និងUpload រូបភាពសកម្មភាពការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន២៣៥ប្រធានបទ<br>+ការងារផ្សេងៗ:<br>- រៀបចំ និងចងក្រងសៀវភៅជាភាសាអង់គ្លេស ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្ររាជកិច្ច សរុបចំនួន៥៩ក្បាល និងបញ្ចូលសៀវភៅច្បាប់តាម E-Library សរុបចំនួន២,១៦៧ក្បាល ដែលមានអ្នកចូលអានចំនួន១,០១១នាក់ ។ |

II.**ទិសដៅការងារខែកញ្ញា ឆ្នាំ២០១៦**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៩៖

-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ ស្តីពីប្រព័ន្ធធ្វើងកាត់គយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសម្រួលការដឹកជញ្ជូនធ្វើងកាត់ទំនិញ

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

+ កិច្ចព្រមព្រៀងស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន

+ ពិធីសារស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន

+ ពិធីសារស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ ដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា

-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែងនិងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងថ្មី ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត-ក្រុងនិងពិធីទទួលសារតាំងទូតថ្មី

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

+ រៀបចំការចុះហត្ថលេខាលើ MOU សហប្រតិបត្តិការជាមួយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឥណ្ឌា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប៉ាគីស្ថាន នៅខែកញ្ញា និងខែវិច្ឆិកា ឆ្នាំ២០១៦

-រៀបចំការបណ្តុះបណ្តាល PBO និងទំនាក់ទំនងលេខាធិការដ្ឋាន APF អំពីសហប្រតិបត្តិការ

បច្ចេកទេស

-សហប្រតិបត្តិការតំបន់ (ត្បូង ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ (ជំហានទី២)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ព្រមទាំងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស

-បន្តសកម្មភាពសហប្រតិបត្តិការការងារជាមួយដៃគូនានា៖ SES, CIM, KAS, GIZ, MARC PLAN FOUNDATION, UNESCO និង KOICA ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

- កសាងបូង់អគារសាលប្រជុំចាស់ ថ្មី និងការរៀបចំបរិវេណ អគារថ្នាក់ដឹកនាំ

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តន៍តាមអង្គភាព និងការបណ្តុះបណ្តាល ព្រមទាំងបានអនុវត្តកម្មវិធី E-បណ្ណាល័យ និងEបណ្ណសារ

- គ្រប់អង្គភាពចំណុះអគ្គនាយកដ្ឋានទាំង៣ ត្រៀមធ្វើការវាយតម្លៃផែនការប្រតិបត្តិប្រចាំនព្វមាស ឆ្នាំ២០១៦

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមការបោះពុម្ពដំណាច់ឆ្នាំ និងរៀបចំប្រទីប

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រកពពីកូរ៉េ ជប៉ុន ចិន អូស្ត្រាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី និងថៃ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តជាក់ស្តែង

-ការរៀបចំបែងចែកគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៧ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម និងផ្តល់សេវាលើមុខងារផ្សេងៗទៀតជាអាទិ៍៖ មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ។ សកម្មភាពការងារប្រចាំថ្ងៃមានភាពមមាញឹក និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបានដោយរលូន ។ ចំពោះមុខងារតាមដានការអនុវត្តច្បាប់ បានចាត់ចែងកម្មវិធីជួបសវនាការចំនួន០២លើក ។ ដោយឡែកលើមុខងារតំណាង បានចាត់ចែងកម្មវិធីចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្រុម ក្មេងបុរាណ ក្មេងប្រពៃណី ក្រុមប្រឹក្សាឃុំ សង្កាត់ សម្ពោធដាក់ឲ្យប្រើប្រាស់អណ្តូងទឹក ស្រះទឹក និងពិនិត្យសមិទ្ធផលថ្មីៗ នៅរាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ រតនគិរី មណ្ឌលគិរី ត្បូងឃ្មុំ កំពង់ស្ពឺ កណ្តាល ព្រៃវែង និងខេត្តស្វាយរៀង ។ ល ។ ព្រមទាំងកម្មវិធីចុះសួរសុខទុក្ខម្ចាស់ឆ្នោតនៅខេត្តនានា រួមទាំងការរៀបចំវេទិកាថ្នាក់ស្រុក នៅខេត្តត្បូងឃ្មុំ ។ ការអភិវឌ្ឍស្ថាប័នបានបើកទំព័រថ្មីតាមការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាពិសេសអនុវត្តន៍គម្រោងបណ្ណាល័យអេឡិចត្រូនិច ដែលត្រូវបន្តបណ្ណសារអេឡិចត្រូនិច ព្រមទាំងមានផែនការបំពាក់បច្ចេកវិទ្យាសំណង់អគារថ្មី ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិកាន់តែបើកទូលាយដែលជាគុណប្រយោជន៍ដល់ជាតិ និងស្ថាប័ន ។ ការកសាងថវិកាតាមកម្មវិធីឆ្នាំ២០១៧សម្រាប់គ្រប់អង្គភាពត្រូវបញ្ចប់ត្រឹមដំណាច់ខែតុលា ឆ្នាំ២០១៦ ។/

ភ្នំពេញ,ថ្ងៃទី១២ខែកញ្ញា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**